# កិច្ចសម្ភាសន៍របស់ ប៉ាត ឆុំ

**កៈ អ្នកសម្ភាសន៍ ថន រដ្ឋា ខៈ អ្នកត្រូវបានគេសម្ភាសន៍ ប៉ាត ឆុំ**

កៈ បាទ! នៅថ្ងៃនេះគឺថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ ហើយខ្ញុំបាទឈ្មោះ ថន រដ្ឋា គឺជាក្រុមការងាររបស់គម្រោងប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា។ គម្រោងនេះត្រូវបានគាំទ្រដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថា BYU នៅសហរដ្ឋអាមេរិច។ ហើយគម្រោងហ្នឹងមានវេបសាយ cambodianoralhistories.byu.edu ហើយ បើសិនជាអ៊ុំស្រី ឬក៏លោកយាយ ហើយនិងកូនចៅរបស់លោកយាយមានបំណងដើម្បីចូលទៅកាន់វេបសាយហ្នឹង គឺគាត់អាចឃើញរូបថត ហើយនិងការសម្ភាសដែលលោកយាយបានផ្តល់ឱ្យនៅក្នុងថ្ងៃនេះ។ បាទ! អញ្ចឹងគាត់អាចរៀនសូត្រពីលោកយាយផងដែរ។ គោលបំណងនៃការសម្ភាសគឺដើម្បីរក្សាជីវប្រវត្តិរបស់លោកយាយផ្ទាល់ទុកដល់កូនចៅជំនាន់ក្រោយ ហើយកុំឱ្យបាត់បង់។ បាទ! អញ្ចឹងថ្ងៃនេះខ្ញុំមកជួបលោកយាយ ប៉ាត ឆុំ លោកយាយមាន៧២ឆ្នាំ។ បច្ចុប្បន្នលោកយាយរស់នៅក្នុងភូមិចំការសំរោងមួយ សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង។ ហើយលោកយាយចង់សួរលោកយាយទើបមកពីណាដែរមិញ?

ខៈ ខ្ញុំនៅនេះឯង។

កៈ នៅហ្នឹង ប៉ុន្តែលោកយាយមានប្រកបការងារអីទេអីទេ?

ខៈ ខ្ញុំនៅផ្ទះ នៅផ្ទះមើលតែចៅតិចតួច។

កៈ អ៎! មើលចៅ។ ខ្ញុំស្មានតែលោកយាយមកពីលាងចានឯណា?

ខៈ អត់ទេ! កូនទៅលាងចានគុយទាវទើបមក។

កៈ អ៎! កូនធ្វើការផ្នែកហ្នឹងហ្ន៎?

ខៈ ចាំ!

កៈ បាទៗ! លោកយាយសុំជួយជម្រាបឈ្មោះពេញលោកយាយម្តងទៀត? ឈ្មោះអី?

ខ៖ ឈ្មោះ ប៉ាត ផុំ។

ក៖ ចាំទ! លោកយាយមានឈ្មោះហៅក្រៅទេ?

ខ៖ មាន!

ក៖ មានហ្ន?

ខ៖ មានច្រើនណាស់។ ហៅឈ្មោះ យាយវិផង ឈ្មោះ យាយស្ដើងផងអញ្ចឹង។

ក៖ បាទ!

ខ៖ ចាំ!

ក៖ កាលពីនៅតូចលោកយាយមានឈ្មោះអ្វីផ្សេងអត់?

ខ៖ កាលពីនៅតូចបងៗខ្ញុំគាត់ហៅថា ខ្វែក។ ខ្ញុំរស់នៅឯខេត្តកំពង់ស្ពឺឯណោះ។

ក៖ បាទ!

ខ៖ បងៗខ្ញុំឃើញខ្ញុំសម្ដីញែកៗគាត់ហៅខ្ញុំថា តាខ្វែកៗទេ។

ក៖ បាទ!

ខ៖ ដល់មកនេះគេឃើញខ្ញុំស្គមស្វិតអញ្ចឹងគេហៅខ្ញុំ យាយវិត។

ក៖ បាទ!

ខ៖ ខ្លះគេឃើញខ្ញុំស្ដើងអញ្ចឹងហៅខ្ញុំ យាយស្ដើងអីចឹង។

ក៖ បាទ! អូ! បានន័យថាឈ្មោះរបស់លោកយាយគឺស្របទៅតាមសាច់ឈាមហ្ន?

ខ៖ ចាំ! ហើយបើភាគច្រើននៅម្ដុំនេះគេសួររកផុំអត់ឃើញទេ ទាល់តែរកយាយវិតបានឃើញអីចឹង។

ក៖ អ៎!

ខ៖ ចាំ! ទាល់តែអ្នកស្គាល់ឈ្មោះឆ្នាំគោលៗមួយៗទេ។

ក៖ បាទ!

ខ៖ ចាំ! អញ្ចឹងឯង ភាគច្រើនយាយវិតហ្នឹងហ្មង។

ក៖ បាទ! ទាក់ទងនឹងភាសា។ ក្រៅពីភាសាខ្មែរ តើអ៊ុំស្រីមានអាចនិយាយភាសាអីផ្សេងទៀតបានទេ?

ខ៖ អត់បានទេកូន អត់ចេះផង។ ចេះតែខ្មែមួយមុខហ្នឹងឯង។ អត់បានរៀនសូត្ររៀនអីហ្នឹងគេផងពីដើម។

ក៖ ចុះភាសាខ្មែរអាចអានបានសរសេរបានទេ?

ខ៖ អានបានតិចៗ។

ក៖ សរសេរបានតិចៗដែរ?

ខ៖ ចាំ! ប៉ុន្តែឥឡូវសរសេរអត់កើតទេ?

ក៖ បាទ!

ខ៖ ព្រោះបាត់យូរពេកទៅ ឥឡូវបាននៅក៏មើលមិនឃើញ។

ក៖ សូមអ៊ុំស្រីជួយជម្រាបអាយុម្តងទៀត?

ខ៖ ៧២ឆ្នាំ។

ក៖ បាទ! បើសិនជាយើងគិតជាឆ្នាំខ្មែរ។ ឆ្នាំអីដែរ?

ខ៖ ឆ្នាំ! មើលឆ្នាំខាល។ ត្រូវអត់?

ក៖ ឆ្នាំខាល?

ខ៖ ចាំ!

ក៖ ខែអ្វី?

ខ៖ ខែពិសាខ។

ក៖ ថ្ងៃអ្វី?

ខ៖ ថ្ងៃសុក្រ។

ក៖ បាទ! ហើយស្រុកកំណើតរបស់អ៊ុំស្រីនៅណាដែរ?

ខ៖ នៅកំពង់ស្ពឺ។

ក៖ នៅកំពង់ស្ពឺ។ ខេត្តអី? ឃុំអី?

ខ៖ ខេត្តកំពង់ស្ពឺ ឃុំរាំងគ្រើ ភូមិត្រពាំងត្រាវ។

ក៖ បាទ! ត្រពាំងត្រាវណ៎?

ខ៖ ចាំ!

ក៖ ហេតុអ្វីបានគេដាក់ឈ្មោះភូមិត្រពាំងត្រាវ?

ខ៖ អត់ដឹងផងពីយាយពីតាមក ប៉ុនត្រពាំងហ្នឹងគេដាំត្រាវដឹង? បានគេដាក់អីចឹង។

ក៖ អញ្ចឹងបច្ចុប្បន្នអ៊ុំស្រីរស់នៅក្នុងភូមិអ្វី? ឃុំអ្វីដែរ?

ខ៖ បច្ចុប្បន្នឥឡូវនេះអ្វី?

ក៖ បាទ!

ខ៖ នៅខេត្តបាត់ដំបង ស្រុកបាត់ដំបង ឃុំចំការសំរោង ភូមិចំការសំរោង១។

ក៖ បាទ!

ខ៖ ក្រុមទី២០។

ក៖ អ៎! ស្គាល់ក្រុមទៀត?

ខ៖ ចាំ!

កៈ បាទ! អញ្ចឹង ហេតុអីបានជាអ៊ុំស្រីបានផ្លាស់ពីទីនោះ ហើយមកនៅទីនេះវិញ?

ខៈ តាំងពីជំនាន់ប៉ុលពតមក។ ខ្ញុំគេបញ្ជូនមកនេះមក ដល់ពេលមកនៅនេះខ្ញុំខ្ជិលទៅស្រុកវិញ ខ្ញុំមកនៅនេះរហូតតាំងពី៧៩មក។

កៈ បាទ! អញ្ចឹងបើសិនជាអត់ត្រឡប់ទៅស្រុកវិញ ចុះដីស្រែដីផ្ទះអីហ្នឹងធ្វើមិចទៅ?

ខៈ គេយកអស់ហើយ។

កៈ បាទ! ចុះមកដល់ទីនេះដំបូងមានអីខ្លះ?

ខៈ អត់មានអីផង។ ខ្ញុំសុំតូបសាច់ជ្រូកចិនផ្សារនៅ។

កៈ បាទ!

ខៈ ចាំ! សុំតូបសាច់ជ្រូកចិនផ្សារនៅ កូនខ្ញុំ៣នាក់ដល់ដែលនេះខ្ញុំខំរកទៅណាំ។

កៈ បាទ!

ខៈ រកទាំងយប់រកទាំងថ្ងៃកូនខ្ញុំនៅតូចៗទេ ហើយបានខ្ញុំសន្សំលុយបាន ខ្ញុំទិញដី។

កៈ ទិញដីបាន១ប្លង់។

ខៈ ចាំ! ទិញដីបាន១ប្លង់។ រួចបានខ្ញុំធ្វើខ្ទមនៅ។

កៈ បាទ!

ខៈ ខ្ទមខ្ញុំ! មានតែប្រក់ស្លឹកដូងទេ។ ស្លឹកដូងបង្គោរត្រសរអី? ស្លឹកដូងទាំងអស់ ទៅបានខ្ញុំរកៗទៅបានធ្វើខ្ទមមួយប្រក់ស្បូវ ដល់ខ្ញុំរកៗទៀតបានខ្ញុំកូនខ្ញុំធំឡើងទៅបានធ្វើផ្ទះមួយ។ ហើយនេះកូនខ្ញុំធ្វើក្រោយទេ ដល់គេមានប្តីមានអីទៅណាំ។

កៈ បាទ!

ខៈ ខ្ញុំមានជួលដី ហើយនិងផ្ទះតែប៉ុណ្ណឹង។

កៈ បាទ!

ខ៖ ខ្ញុំនៅតូបសាច់ជ្រូកចិនផ្សារហ្នឹងទេ។

ក៖ នៅប៉ុន្មានឆ្នាំបានផ្ទះខ្លួនឯង?

ខ៖ ខ្ញុំនៅ៤ទៅ៥ឆ្នាំ។

ក៖ បាទ!

ខ៖ ៤ទៅ៣ឆ្នាំបាន បានដីនេះ ហើយខ្ញុំធ្វើរោងនៅហ្នឹង ហើយបានខ្ញុំរកទៀត។ រកទៀត៥ទៅ៦ឆ្នាំទៀតទៅ ខ្ញុំសន្សំលុយបានធ្វើផ្ទះនេះ ហើយដល់ធ្វើផ្ទះហ្នឹងហើយកូនធំៗទៅថា ដាំបន្លែ ដាំអីទៅ ខ្លះធ្វើការរោងចក្រអីទៅបានតរហូត ទៅកូន។

ក៖ បាទ! ស្រះនេះ ស្រះពីណាគេ?

ខ៖ ស្រះគេ ស្រះគេរួមតែឥឡូវគេចែកគ្នាអស់ហើយ។

ក៖ បាទ!

ខ៖ ខ្ញុំទិញដីគេទៅ ទិញបានតែដីគេអត់ឱ្យស្រះទេ។

ក៖ បាទ!

ខ៖ តែបើប្រើទឹកប្រើបាន។

ក៖ គេឱ្យទឹកប្រើហ្ន៎?

ខ៖ ចាំ!

ក៖ ទាក់ទងនឹងអាពាហ៍ពិពាហ៍វិញ។ តើប្តីរបស់អ៊ុំស្រីឈ្មោះអ្វីដែរ?

ខ៖ ប្តីខ្ញុំនៅនេះ អត់និយាយប្តីមុនទេ។

ក៖ បាទ!

ខ៖ ប្តីក្រោយនេះបានទើប៧៩នេះទេ។

ក៖ ៧៩ហ្ន៎?

ខ៖ ចាំ!

ក៖ គាត់ឈ្មោះអ្វី?

ខ៖ ឈ្មោះ ប៉ុន។

ក៖ បាទៗ!

ខ៖ គាត់ខូចយូរហើយ។

ក៖ ហើយស្គាល់គ្នាប៉ុន្មានឆ្នាំហើយ? បានយកគ្នាជាគូ?

ខ៖ ស្គាល់គ្នាប្រហែលជា២ឆ្នាំហើយដឹង ម៉ែឪគាត់ស្រឡាញ់ខ្ញុំអាណិតខ្ញុំ ឃើញក៏គាត់អត់ឱ្យខ្ញុំទៅស្រុករៀបសែនរៀបអីឱ្យអីចឹង។ ចាយអង្ករ ចាយអង្ករណាកូន។

ក៖ បាទ!

ខ៖ មិនទាន់មានចាយលុយ ចាយអង្ករ។ គាត់រៀបសែនរៀបអីទៅគាត់នៅមើលរហូតអញ្ចឹងទៅ នៅខាងពោធិ៍ឯណោះទេ។

ក៖ បាទ!

ខ៖ អានេះខ្ញុំអត់មានគោមានស្រែ មានអីខ្ញុំរកផ្សារ ទៅផ្សារយើងរកមួយថ្ងៃបានហូប។ បើនៅស្រែអត់ទេ ស៊ីតែឈ្នួលគេ អស់ពីស្ទូងចូលច្រូត អស់ច្រូតចូលស្ទូង។

ក៖ បាទ!

ខ៖ ហើយបើមកនៅស្រែ អេំ! មកនៅផ្សារអញ្ចេកយើងលើកឥវ៉ាន់បន្លែគេលក់ទៅបានហូបភ្លាមៗ។

ក៖ បាទ!

ខ៖បានរស់ស្រួល។

ក៖ អញ្ចឹងខាន់ស្លាប៉ុន្មានដែរ?

ខ៖ ខាន់ស្លាអត់មានផង សែនចាស់ៗគាត់រៀបឱ្យ។

ក៖ បាទ!

ខ៖ ចាំ! កាលហ្នឹង៧៩ម្លេះ។

ក៖ សម្រាប់អ៊ុំស្រីផ្ទាល់ មូលហេតុអីបានជាអ៊ុំស្រីសម្រេចចិត្តយកអ៊ុំប្រុសជាគូ?

ខ៖ តាមចាស់ៗ។

ក៖ បាទ!

ខ៖ អ៊ុំធមិខ្ញុំគាត់ឱ្យទៅ។ គាត់ថាអត់ឱ្យទៅទេគាត់រៀបទុកដាក់ប្ដីសីនេះឱ្យហើយៗ ចាំស្រុកស្រួលបួលចាំឱ្យទៅរកបងប្អូន ព្រមតាមគាត់ទៅ។

ក៖ ហើយអញ្ចឹងពេលគាត់បានយើងជាគូហើយ។ តើអ៊ុំស្រីស្រឡាញ់អ៊ុំប្រុសលក្ខណៈត្រង់ណា?

ខ៖ ស្រឡាញ់ទាំងចិត្តគាត់ចេះនិយាយស្ដីថ្នមថ្នាក់អីចឹង ចេះរកហូបចុក។

ក៖ បាទ!

ខ៖ រកត្រីរកអីៗចឹងទៅ។ ធ្វើស្រែធ្វើអី ចេះចិញ្ចឹមគ្នាទៅវិញទៅមក។ គាត់រកត្រីបានយកទៅលក់ទៅ។

ក៖ បាទ!

ខ៖ ហើយខែច្រូតឡើង ដើរស៊ីឈ្នួលច្រូតគេអីចឹងទៅ។

ក៖ បាទ! អញ្ចឹងទាក់ទងបងប្អូនរបស់អ៊ុំស្រីវិញម្ដង។ តើអ៊ុំស្រីមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានបងប្អូន៦នាក់ ប៉ុន្តែខូចអស់៣ហើយ នៅសល់៣។

ក៖ បាទ! ហើយអ៊ុំស្រីជាកូនទីប៉ុន្មាន?

ខ៖ ខ្ញុំកូនទី៣។

កៈ កូនពៅហ្ន៎?

ខៈ ចាំ!

កៈ កូនទី៦?

ខៈ កូនទី៦។

កៈ បាទ! អ៊ុំស្រីជួយជម្រាបឈ្មោះបងប្អូនរបស់អ៊ុំស្រីបានទេ? ថាគាត់ទី១ឈ្មោះអី? ហើយគ្រួសារគាត់នៅណា? ឈ្មោះអី?

ខៈ ចាំ! បងប្រុសខ្ញុំបួស បងស្រីខ្ញុំតែមួយទេ។ ទាំងអស់៦តែស្លាប់អស់ហើយ នៅ១ឈ្មោះ ប៉ាត ញ៉េ ១ឈ្មោះ ប៉ាត ញង ២ឈ្មោះ ប៉ាត ឆិល។

កៈ បាទ!

ខៈ ចាំ! មួយទៀតឈ្មោះ ប៉ាត់ យឿន មួយទៀតឈ្មោះ ប៉ាត យួន។

កៈ បាទ!

ខៈ ចាំ! ហើយខ្ញុំ ប៉ាត ឆុំ។

កៈ ប៉ាត ឆុំ?

ខៈ ចាំ! ដែលនៅសព្វថ្ងៃនៅតែខ្ញុំ នៅប៉ាត ញងមួយ ប៉ាតយឿនមួយ ខ្ញុំមួយ ប៉ាត ឆុំ។

កៈ បាទ!

ខៈ តែគេនៅឯណោះ នៅភ្នំពេញ។

កៈ បាទ! អញ្ចឹងគ្រួសាររបស់គាត់ ចាំឈ្មោះគ្រួសាររបស់គាត់ទេ?

ខៈ ចាំតើ!

កៈ ឈ្មោះអ្វីខ្លះ? ហើយគាត់មានកូនប៉ុន្មាននាក់ហើយ?

ខៈ បងថ្លៃខ្ញុំ ក៏ខូចដែរ នៅតែកូន។ បងខ្ញុំក៏ខូចបងថ្លៃខ្ញុំក៏ខូច។

កៈ បាទ!

ខៈ ចាំ! បងដែលបងគេហ្នឹង! មានកូនស្រី៣។

កៈ បាទ!

ខៈ ឈ្មោះ សារុម សារ៉ាន អាមុំ។ ចាំ! នៅឯស្រុកណោះ នៅត្រពាំងត្រាវរាល់ថ្ងៃហ្នឹង។

កៈ បាទ!

ខៈ ហើយបងបន្ទាប់ពីបងញ៉េហ្នឹងមក ឈ្មោះ ស្លួញ អាយេន អាបារាំង សីយូន។

កៈ បាទ!

ខៈ ចាំ! ហ្នឹងហើយ។ ហើយបន្ទាប់ទៀតមកស្លាប់កាលអាពតអស់ហើយ ប្រពន្ធទាំងកូនទាំងអស់ ហើយបន្ទាប់ខ្ញុំហ្នឹងមានមួយ មានកូននៅសល់១។

កៈ បាទឈ្មោះអ្វី?

ខៈ ឈ្មោះ បញ្ញា។

កៈ ចុះឥឡូវបញ្ញានៅឯណា?

ខៈ បញ្ញានៅឯកំពង់ស្ពឺហ្នឹង ខាងជិតកំពង់ត្រាំ។

កៈ បាទ!

ខៈ ចាំ!

កៈ គាត់មានគ្រួសារនៅ?

ខៈ មានហើយ។

កៈ បាទ! គាត់បានបន្តត្រកូលហ្ន៎?

ខៈ ចាំ! បានបន្តត្រកូលមួយ។

កៈ ឥឡូវមានកូនប៉ុន្មានហើយ?

ខៈ កូន២ មិនដឹងមានប៉ុន្មានទៀតហើយទេ?

កៈ ចាំឈ្មោះគាត់?

ខៈ ចាំ!

កៈ ចាំឈ្មោះចៅៗអត់?

ខៈ អត់ទេ! អត់ចាំផង ហើយមួយទៀតឈ្មោះ យឿន។

កៈ បាទ!

ខៈ យឿនកូនគាត់តែហៅក្នុងក្រៅមិនដឹងទេណា៎ តែដែលនៅដែលហៅពីដើមមកឈ្មោះ ប៉ាត ថុល១។

កៈ បាទ!

ខៈ ប៉ាត ម៉ៅ១ ប៉ាត ពឹម១ ប៉ាតគិត១ ប៉ាត ទូច១ ប៉ាត មុំ១ ប៉ាត សារឿន១។

កៈ បាទ!

ខៈ ចាំ៨។

កៈ ៨នាក់ហ្ន៎?

ខៈ ចា៎!

កៈ អូ! ច្រើន។ នេះចៅមែន?

ខៈ ចៅ!

កៈ អញ្ចឹងបងប្អូនដែលគាត់ស្លាប់។ មុនគាត់ស្លាប់សម័យពពតហ្នឹង តើគាត់មានគ្រួសារអត់?

ខៈ មាន!

កៈ មានហ្មុំ?

ខៈ ចាំ! មានហើយក៏ស្លាប់អស់ទៅណាំ។

កៈ បាទ!

ខៈ ចាំ! ផុតពូជ១សំបុកហ្នឹង។

កៈ ស្លាប់ទាំងសំបុកហ្មុំ?

ខៈ ចាំ! មួយសំបុកនៅសល់១។

កៈ អ៎! អញ្ចឹងគាត់អត់មាននៅសល់ ប៉ុន្តែ១សំបុកហ្នឹងទៅទាំងអស់ហ្មុំ?

ខៈ ចាំ! ទៅទាំងអស់។

កៈ បាទ!

ខៈ ហើយ១សំបុកទៀតនៅសល់តែ១ទេ។

កៈ បាទ! អញ្ចឹងម្តាយរបស់អ៊ុំស្រីឈ្មោះអីដែរ?

ខៈ ឈ្មោះ អៀង លក។

កៈ បាទ! ហើយស្រុកកំណើតគាត់នៅឯណា?

ខៈ នៅឯត្រពាំងត្រាវកំពង់ស្ពឺ។

កៈ អញ្ចឹងឪពុករបស់អ៊ុំស្រីឈ្មោះអីដែរ?

ខៈ ឈ្មោះ យូ ប៉ាត។

កៈ យូ ប៉ាតហ្មុំ?

ខៈ ចាំ!

កៈ ស្រុកកំណើតគាត់នៅឯណាដែរ?

ខ៖ នៅហ្នឹងដែរ។

ក៖ នៅហ្នឹងដែរ?

ខ៖ នៅជាមួយគ្នា។

ក៖ ពួកគាត់ទាំង២ ពីដើមប្រកបមុខរបរអីដែរ?

ខ៖ ធ្វើស្រែ ឡើងត្នោត។

ក៖ អ៎! ធ្វើស្រែឡើងត្នោតហ្ន៎?

ខ៖ ចា៎!

ក៖ បាទ!

ខ៖ ឪខ្ញុំគាត់ឡើងត្នោត។ ថ្ងៃឡើងត្នោតៗ ថ្ងៃធ្វើស្រែៗ។ ធ្វើស្រែចិញ្ចឹមគោ ចិញ្ចឹមអីធម្មតា។

ក៖ បាទ! ចិញ្ចឹមគោ ចិញ្ចឹមអីទៀតហ្ន៎។

ខ៖ ចា៎!

ក៖ ឪពុករបស់អ៊ុំស្រី។ ឪពុកម្ដាយខាងឪពុករបស់អ៊ុំស្រីឈ្មោះអីដែរ?

ខ៖ ឪពុកខ្ញុំឈ្មោះ យូ ប៉ាត ហើយម៉ែខ្ញុំឈ្មោះ យ៉ា ហើយម៉ែខ្ញុំឈ្មោះ អៀង លក។

ក៖ បាទ!

ខ៖ អៀង យាយលក។

ក៖ យូ ប៉ាតហ្នឹងជាអ្នកណា?

ខ៖ ជាឪពុកខ្ញុំ។

ក៖ បាទ! ចុះឪពុកម្ដាយខាងឪពុកឈ្មោះអី?

ខ៖ អត់ស្គាល់ផង! កើតអត់ឃើញយាយផង។

កៈ ចុះឪពុកម្ដាយខាងម្ដាយស្គាល់អត់?

ខៈ ឈ្មោះអ្វីទេ? ឈ្មោះ យាយចឹក។ យាយចឹក! តាអៀង។

កៈ យាយចឹក តាអៀង?

ខៈ ចាំ!

កៈ ខាងឪពុក?

ខៈ ហ្នឹងៗហើយយាយខ្ញុំណា?

កៈ បាទ!

ខៈ ហ្នឹងហើយ!

កៈ ខាងម្ដាយឈ្មោះ?

ខៈ ខាងឪពុកអញ្ចែក! តាយូ យាយសែ។

កៈ បាទ!

ខៈ ហើយខាងម្ដាយឈ្មោះ តាអៀង យាយចឹក។

កៈ តាអៀង យាយ?

ខៈ យាយចឹក។

កៈ យាយចឹក?

ខៈ ចាំ!

កៈ អំ!

ខៈ អញ្ចឹងណា។

កៈ តាៗគាត់ប្រកបមុខរបរអីដែរ?

ខ៖ គាត់ធ្វើតែស្រែ។ ចាស់ពីដើមអត់មានធ្វើអីផង។

ក៖ បាទ!

ខ៖ ធ្វើស្រែ ចិញ្ចឹមគោ ឡើងត្នោតអីអញ្ចឹងទៅ។

ក៖ បាទ!

ខ៖ ស្គាល់តែត្រឹមតាប៉ុន្នឹងឯង។

ក៖ ប៉ុណ្ណឹងឯងហ្ន៎?

ខ៖ ស្គាល់តាទួតទៀតផង។ គ្រាន់តែលៃឈ្មោះទេកូន?

ក៖ បាទ!

ខ៖ អត់ឃើញមុខទេ។

ក៖ ម្ដាយរបស់អ៊ុំស្រី គាត់មានបានបងប្អូនប៉ុន្មាននាក់?

ខ៖ បងប្អូនគាត់មាន៣នាក់។

ក៖ បាទ!

ខ៖ ចាំ! ឈ្មោះអីទូចទេ? អត់ស្គាល់ បែបឈ្មោះដូចគ្នាដឹង ឈ្មោះ អៀង ទូច។

ក៖ បាទ!

ខ៖ ចាំ! អៀងអីទេនៅឯណោះ? ឈ្មោះអីទេអាអូនភ្លេចអស់ហើយ។

ក៖ បាទ! ដឹងថាប៉ុន្មាននាក់អត់?

ខ៖ ចាំ! ដឹងតែ៣។

ក៖ បាទ! ៣នាក់ហ្ន៎?

ខ៖ ចាំ!

កៈ ប្រុសប៉ុន្មាន? ស្រីប៉ុន្មាន?

ខៈ ប្រុស២ ស្រី១។

កៈ បាទ!

ខៈ ចា៎!

កៈ អញ្ចឹងខាងម្ដាយមានបងប្អូនប៉ុន្មាននាក់?

ខៈ ខាងម្ដាយខ្ញុំហ្នឹងមានតែ៣នាក់ហ្នឹងឯង។

កៈ ចុះខាងឪពុកមានប៉ុន្មាននាក់?

ខៈ ខាងឪពុកមាន អ៊ំស្វ អ៊ំជិត។

កៈ បាទ!

ខៈ ហើយអ្នកណាទៀតទេកូន? ភ្លេចហើយយូរពេក។

កៈ ដឹងថាមានប៉ុន្មាននាក់ទេ?

ខៈ ចា៎! ហ្នឹងស្គាល់គាត់តែសារមកឃើញតែ២ហ្នឹងឯង។

កៈ តែ២ហ្នឹង?

ខៈ ចា៎!

កៈ បាទ! ឥឡូវនេះ តើអ៊ំស្រីមានសាច់ញាតិ ឬក៏បងប្អូនរស់នៅក្រៅប្រទេសទេ?

ខៈ អត់ទេកូន អត់ទេ។

កៈ អត់មានទេហ្ន៎?

ខៈ ចា៎!

កៈ បាទ! អញ្ចឹងតើអ៊ុំស្រី ឬក៏លោកយាយមានកូនប៉ុន្មាននាក់ហើយ?

ខ៖ ខ្ញុំមាន៣កូនខ្ញុំ។

ក៖ កូនបី?

ខ៖ ចាំ!

ក៖ ប្រុសប៉ុន្មាន? ស្រីប៉ុន្មាន?

ខ៖ ស្រីទាំង៣។

ក៖ ស្រីទាំង៣?

ខ៖ ចាំ!

ក៖ អ្នកទី១គាត់ឈ្មោះអី?

ខ៖ អ្នកទី១ឈ្មោះ ពុត បូរ៉ា។

ក៖ គាត់មានគ្រួសារនៅ?

ខ៖ មានហើយ។

ក៖ ស្វាមីគាត់ឈ្មោះអ្វី?

ខ៖ ឈ្មោះ យ៉ង់ សារឿន។

ក៖ ពួកគាត់ទាំង២មានកូនប៉ុន្មាន?

ខ៖ មានកូន៣។

ក៖ ពួកគាត់ទាំង២ប្រកបមុខរបរអ្វីខ្លះ?

ខ៖ គាត់! កូនខ្ញុំធ្វើការរោងចក្រ។

ក៖ បាទ! ហើយទាំង៣នាក់ ដែលជាកូនរបស់គាត់ហ្នឹង។ តើឈ្មោះអ្វីខ្លះ?

ខ៖ ឈ្មោះ ញានអី? ញាន សុនីតា។

កៈ ញាន សុនីតា?

ខៈ ចាំ! ហើយទី២ឈ្មោះ ញាន សុវណ្ណត្រា។

កៈ បាទ!

ខៈ ហើយទីបីឈ្មោះ ញាន វ៉ាន់ទ្រី។

កៈ យ៉ា! ឈ្មោះពិរោះៗណាស់។

ខៈ ចាំ!

កៈ ចុះកូនទី២គាត់ឈ្មោះអ្វីដែរ?

ខៈ កូនទី២ឈ្មោះ ពុត វណ្ណារី។

កៈ ប្តីរបស់គាត់ឈ្មោះអ្វី?

ខៈ ឈ្មោះ ចាន់ ធឿន។

កៈ ពួកគាត់ទាំង២មានកូនប៉ុន្មាន?

ខៈ មានកូន១នេះឯង។

កៈ បាទ! កូន១អាយុប៉ុន្មាន?

ខៈ អាយុ១២ឆ្នាំ។

កៈ ឈ្មោះអ្វីគេ?

ខៈ ឈ្មោះ ធឿន រីយ៉ា។

កៈ បាទ! គាត់រីយ៉ានៅរៀនអី?

ខៈ ចាំ! រៀន។

កៈ បាទ!

ខ៖ រៀនរាល់ថ្ងៃ។

ក៖ ចុះគាត់ទាំង២ប្រកបមុខរបរអីគេដែរ?

ខ៖ រាល់ថ្ងៃនៅលក់ផ្លែឈើនៅរោងចក្រនៅកំពង់ស្ពឺ។

ក៖ អ៎! ឆ្ងាយ។

ខ៖ ចា៎!

ក៖ យូរៗមកលេងផ្ទះម្ដងហ្ន៎?

ខ៖ ចា៎!

ក៖ ចុះកូនទី៣?

ខ៖ កូនទីបី ឈ្មោះ ពុត វណ្ណា។

ក៖ ពុត វណ្ណាគាត់ ប្ដីគាត់ឈ្មោះអ្វី?

ខ៖ ប្ដីគាត់ឈ្មោះ សរ ផានី។

ក៖ បាទ! ហើយពួកគាត់ប្រកបការងារមុខរបរអ្វីដែរ?

ខ៖ កូនប្រសារខ្ញុំវាដើរធ្វើភ្លើងធ្វើអីឱ្យគេ។ តភ្លើង តអីតាមផ្ទះ តាមសណ្ឋាគារអីទៅកូន។

ក៖ បាទ! អញ្ចឹងពួកគាត់មានកូនប៉ុន្មាននាក់ដែរ?

ខ៖ មានកូន៣។

ក៖ កូន៣?

ខ៖ ចា៎!

ក៖ ឈ្មោះអ្វីខ្លះ?

ខ៖ ឈ្មោះ នី វ៉ាន់នាថ។

កៈ បាទ!

ខៈ ហ្នឹងហើយ ហើយនិង នី វីសា។

កៈ បាទ!

ខៈ ហើយ នី វណ្ណាក់។

កៈ បាទ!

ខៈ ចាំ! កូនតែ៣ហ្នឹង។

កៈ ឈ្មោះសុទ្ធតែកាលីបៗ។

ខៈ ចាំ! ពេទ្យគាត់ដាក់អោយ។

កៈ អំ! ពេទ្យដាក់អោយទៀត?

ខៈ ចាំ!

កៈ អរគុណដែលបានជម្រាបអំពីកូនៗ។ ចុះប្ដីឈ្មោះអីមិញ?

ខៈ ណា?

កៈ ប្ដី!

ខៈ សរ ផានី។

កៈ ប្ដីរបស់អ៊ុំស្រី?

ខៈ ប្ដីខ្ញុំឈ្មោះ យូ ប៉ាត។

កៈ បាទ! អញ្ចឹងឪពុកម្ដាយរបស់គាត់ឈ្មោះអី?

ខៈ ឪពុកគាត់ឈ្មោះ យូ គាត់ឈ្មោះ ប៉ាត។ ម្ដាយគាត់ឈ្មោះ អៀង អញ្ចឹងឯង។

កៈ តាយូ យាយអៀង។ គាត់ប្រកបមុខរបរអីសព្វថ្ងៃ?

ខ៖ គាត់ធ្វើស្រែ ធ្វើតែស្រែ។

ក៖ បាទ! អញ្ចឹងប្តីរបស់យាយគាត់មានបងប្អូនប៉ុន្មាននាក់អ៊ុំស្រី?

ខ៖ បងប្អូនគាត់២នាក់ដែលស្លាប់អស់ហើយ ស្លាប់ទាំងអស់ហ្នឹង។

ក៖ អ៎!

ខ៖ ចាំ!

ក៖ អត់មានសល់អីទេហ្ន៎?

ខ៖ អត់ទេ។ មានតែ២ហ្នឹងឯងស្លាប់អស់សម័យអាពត។

ក៖ សុំជួយជម្រាបម្តងទៀតអំពីសុខភាពរបស់អ៊ុំស្រី ឬក៏លោកយាយ?

ខ៖ ចាំ! សុខភាពខ្ញុំរាល់ថ្ងៃឈឺចុកចាប់ខ្នង ឈឺឆ្អឹងខ្នង។

ក៖ ឈឺឆ្អឹងខ្នងចង្កេះ។ ឧស្សាហាត់ប្រាណអត់?

ខ៖ ហាត់ដែរ ប៉ុនវាឈឺតែតាហ្នឹង។

ក៖ បាទ!

ខ៖ ដើបអត់រួចទេ ដេកភ្លៀង ហើយឆ្អឹងជំនីនេះ។

ក៖ បាទ!

ខ៖ នៅម្តុំហ្នឹងឯង លាបរិតរាល់ថ្ងៃ។

ក៖ អ៎! បានអីលាប?

ខ៖ លាបប្រេងល្ង។

ក៖ បាទ!

ខ៖ ហើយផឹកថ្នាំសរសៃប៉ុណ្ណឹងឯង។

កៈ បាទ!

ខៈ លាបថ្នាំពេទ្យទៅវារមូលអស់ហើយ ឥឡូវសម្រាកសិន។

កៈ អញ្ចឹងកាលពីតូចលោកយាយរៀននៅឯណា?

ខៈ ខ្ញុំរៀនបន្តិចបន្តួចនៅសាលាឯផ្ទះណោះ។

កៈ បាទ! ឈ្មោះសាលាអីគេ?

ខៈ សាលាអង្គសាងៃ។

កៈ អង្គសាងៃ?

ខៈ ចាំ! វត្តអង្គសាងៃ។

កៈ បានប៉ុន្មាន? រៀនបានត្រឹមណា?

ខៈ រៀនទើបថ្នាក់ទី១២។

កៈ បាទ!

ខៈ ថ្នាក់ទី! ហើយស្អីគេ?

កៈ បន្ទាប់មកថ្នាក់ទី១១។

ខៈ ១១មក១០អញ្ចឹងអី?

កៈ បាទ!

ខៈ ប៉ុណ្ណឹងឯង។

កៈ បានត្រឹមទី១០ហ្ន៎?

ខៈ ចាំ!

កៈ បាន៣ថ្នាក់ដែរតើ?

ខ៖ ចាំ! រៀនបានក្នុងកុដលោក។

ក៖ ខ្ញុំទើបតែដឹងដែរថា៖ សម័យមុនគេរាប់ពីទី១២មក១១ដល់១០។

ខ៖ ចាំ!

ក៖ អញ្ចឹងទៅណាំ សម័យឥឡូវគេរាប់ទី១ទី២ឡើងទៅវិញ។

ខ៖ អត់មានសាលារៀនផង រៀនក្រោមកុដលោក លោកបង្រៀនហ្នឹង។

ក៖ បាទ!

ខ៖ចាំ! អត់មានគ្រូសោះ លោកបង្រៀន។

ក៖ បាទ! ហើយអ៊ុំស្រី ឬក៏លោកយាយចាំមិត្តភក្តិដែលរៀនជាមួយគ្នាទេ?

ខ៖ អត់ចាំទេ ទៅណាទៅណីឆ្ងាយៗពីគ្នា។

ក៖ បាទ!

ខ៖ ចាំ!

ក៖ សម្រាប់លោកយាយផ្ទាល់សព្វថ្ងៃ និង ពីមុនខុសប្លែកគ្នាមិចដែរ?

ខ៖ ខុសប្លែកស្រួល មានផ្លូវដើរខ្វាត់ខ្វែង មានភ្លើង ទឹក ចាស់។

ក៖ ឥឡូវក៏ស្រួលជាងមុន?

ខ៖ ចាំ! មានកន្លែងរកស៊ីធ្វើការ។

ក៖ បាទ!

ខ៖ កូននេះ ចូលរោងចក្រទៅធ្វើអីក៏ធ្វើទៅ ស្រួលជាងកាលមុន កាលមុនយើងធ្វើតែស្រែ ចិញ្ចឹមគោ ចិញ្ចឹមជ្រូក ប៉ុណ្ណឹងឯង។

ក៖ បាទ!

ខ៖ ហើយដើរទូរទឹក អ៎! ងូតទឹកតាំងពីម៉ោង៩ដាក់ក្អម ឥឡូវអត់ទេកន្លែងណាក៏មានដាក់ទឹក។

ក៖ ទឹកដាក់ក្អមទៀតហ្ន៎?

ខ៖ ចា៎! ទូលក្អម។

ក៖ បាទ!

ខ៖ ហើយឆ្ងាយៗ។

ក៖ ទម្រាំហ្នឹងបានទឹកមក?

ខ៖ ចា៎! ឆ្ងាយណាស់។ ឥឡូវអត់ទេទឹកមកដល់ស្រួលណាស់។

ក៖ បាទ! ទាន់សម័យជាងមុនហ្ន៎?

ខ៖ ចា៎! អូ! គ្រាន់លើសហ្នឹង។

ក៖ និយាយរួមស្រួលជាងពីមុនឆ្ងាយ?

ខ៖ ចា៎! ស្រួលលើសពីមុនឆ្ងាយ។

ក៖ បាទ!

ខ៖ ការងារក៏មានធ្វើ។

ក៖ សម្បូរការងារទៀត?

ខ៖ សម្បូរការងារធ្វើ ហើយសាលារៀន។

ក៖ សាលារៀនមានច្រើនទៀត?

ខ៖ ចា៎! មានច្រើនបង្រៀនអីរៀនទៅ រៀនភាសាអង់គ្លេស ថៃ ចិន ជប៉ុន អីណាទៅ។

ក៖ ឱ្យតែមានពេល មានលុយ?

ខ៖ ចាំ! ឱ្យតែមានពេល មានលុយ។ កាលហ្នឹងអត់ទេរៀនល្មមៗទេ ទៅធ្វើស្រែទៅ! អញ្ចឹងបាន កូនអត់ចេះ។ ខ្ញុំអីម៉ែខ្ញុំមិនឱ្យរៀនទេមិនបានរៀនអីទេកូនអើយ យើងស្រី ឈប់ទៅ គ្រាន់តែ មើលឈ្មោះខ្លួនឯងដាច់ទៅបានហើយ។ គាត់ថាអញ្ចឹងឈប់ទៅ ធ្វើស្រែទៅ។

ក៖ បាទ! អញ្ចឹងទាក់ទងទៅហ្នឹង ម្ហូបវិញធ្លាប់បានរៀនជាមួយចំអិនម្ហូបពីឪពុកម្ដាយ ជីដូនជីតាទេ?

ខ៖ អត់ទេ។

ក៖ អត់ទេហ្ន៎?

ខ៖ អត់បានចម្អិនម្ហូបអីទេ នៅស្រែអូន មានតែក្ដាម ខ្យងអី ត្រីសាច់ ព្រលិត ត្រកួន ស្លឹកអំពិល ស្លឹកអាបៀង ត្នោតអីហ្នឹងណាំ មិនដូចពីឥឡូវទេ ឥឡូវខ្ញុំអត់ចេះធ្វើទេ ស្លអ្វើម្ហូបអាហារអី។

ក៖ អ៎! លោកយាយធ្លាប់បានធ្វើរៀនពីពួកគាត់អត់?

ខ៖ អត់! កើតមកឃើញតែគាត់ធ្វើអីចឹង។ ធ្វើតាមគាត់អញ្ចឹងទៅ។

ក៖ ធ្វើតាមគាត់ទៅចេះតាមគាត់ដែរ?

ខ៖ ចាំ! ចេះតែប៉ុន្នឹង។

ក៖ បាទ។

ខ៖ ក្ដាម ខ្យង ចត់ត្រីអីអញ្ចឹងទៅ។

ក៖ អូ! ឆ្ងាញ់ណាស់។ ហើយសម្រាប់លោកយាយផ្ទាល់ លោកយាយចូលចិត្តពិសារម្ហូបអីជាងគេ?

ខ៖ ខ្ញុំចូលចិត្តសម្លម្ជូរ។

ក៖ សម្លម្ជូរ?

ខ៖ ចាំ!

ក៖ កូនៗដឹងថាលោកយាយចូលចិត្តសម្លម្ជូរទេ?

ខ៖ ដឹងតើ។

ក៖ ដឹង! ស្លម្ជូរសាច់អ្វី?

ខ៖ ឥឡូវគេស្លម្ជូរសាច់អីក៏បានដែរ។ ពីមុនខ្ញុំស្លម្ជូរក្តាមបុក យកសំបកវាចេញទៅយកខួរហ្នឹង ស្លជាប្រហុក ស្លជាអាណ្វង ស្លជាល្ពៅអីចឹង។

ក៖ បាទ!

ខ៖ ហើយដាក់ម្អមទៅ ដាក់កូនត្រីតូចៗតិចទៅឆ្ងាញ់។

ក៖ ឱ្យតែម្ជូរ?

ខ៖ ឱ្យតែម្ជូរ។

ក៖ បាទ! ចុះទាក់ទងនឹងចម្រៀងវិញ។ ចម្រៀងចូលចិត្តចម្រៀងបែបសម័យ ឬបែបបុរាណ?

ខ៖ ចូលចិត្តបុរាណ។

ក៖ បាទ! បទអីគេ?

ខ៖ បទអីក៏បានដែរ។

ក៖ ឱ្យតែបុរាណហ្ន៎?

ខ៖ ចាំ! ហ្នឹងខ្ញុំអត់ទាន់ឈឺច្រកេះណាំ។

ក៖ បាទ!

ខ៖ កុំអីខ្ញុំរាំរាល់ថ្ងៃ។

ក៖ ចេះរាំអ្វីខ្លះ?

ខ៖ ស្អីក៏ចេះដែរ។

ក៖ ចេះសារ៉ាវ៉ាន់ ឡាំលាវ ចូកក្រពឺស កន្ទ្រឹម?

ខ៖ ចេះ! អូ! ចេះណាស់ចូលចិត្ត។

ក៖ យ៉ា! អាចបង្រៀនបានអត់?

ខ៖ បង្រៀនមិនបានទេ មិនចេះខ្លួនឯងផង ឮចេះ បើថារាំប្រពោលអីអត់ចេះ ប៉ុននឹកឃើញប្រពោលណាច្រៀង នឹកឃើញខ្ញុំទៅអាហ្នឹងដែរ។

ក៖ អីយ៉ា!

ខ៖ ហ្នឹងហើយ។ និយាយពីនេះកូន វត្តនោះក៏ដោយពេលចូលចិត្តអត់មានអ្នកណារាំ។ ការក៏ដោយអត់មានអ្នកណាហ៊ានចូលរាំ ចាក់បាស់ក្ដឹៗអញ្ជឹង។

ក៖ បាទ!

ខ៖ ខ្ញុំបើកវង់ឱ្យគេ បើកណា? បើកបាន១បទ១ ២បទទៅ។ ក្មេងៗគេចូល ខ្ញុំចេញ ហាត់។

ក៖ បាទ! រាំមុនគេ?

ខ៖ ចាំ! រាំមុនគេអីចឹង តែឥឡូវឈប់។

ក៖ ឥឡូវដាក់មកដល់ពេលហាត់ប្រាណ។

ខ៖ អត់ហ៊ាន។

ក៖ ខ្លាចអី?

ខ៖ ខ្លាចគ្រិចឆ្អឹង។

ក៖ អំ! ខ្លាចចងហាត់ប្រាណ?

ខ៖ ចាំ!

ក៖ ហ្នឹង! ខ្ញុំចូលចិត្តរាំលេងដែរ។

ខ៖ ចាំ! ខ្ញុំចូលចិត្តណាស់។

ក៖ បាទ!

ខ៖ រឿងបាស់រឿងអី? ខ្ញុំចូលចិត្ត។

ក៖ បាទ!

ខ៖ ច្រៀង។

ក៖ អ៊ុំចេះច្រៀងទៀត។ ចេះច្រៀងបទអីខ្លះ?

ខ៖ ច្រៀងបទអ្វី? ឱ្យតែឮមកចេះច្រៀងរហូតហ្នឹង។

ក៖ យ៉ា! ស្ដាប់ៗទៅអាចច្រៀនបានហ្ន៎?

ខ៖ ចាំ!

ក៖ បាទ! អាចប្រណាំងជាមួយ និងហឹមស៊ីវនបានអត់?

ខ៖ អត់បានទេ! កាលហឹមស៊ីវនគាត់ច្រៀងរាល់ថ្ងៃអាជីពគាត់ហ្នឹងឯង។

ក៖ ទាក់ទងនឹងរឿងភាគ លោកយាយចូលចិត្តរឿងភាគអីគេដែរ?

ខ៖ ខ្ញុំចូលចិត្តរឿងបុរាណៗ។

ក៖ បុរាណ?

ខ៖ ចាំ!

ក៖ រឿងថៃ រឿងខ្មែរហ្ន៎?

ខ៖ រឿងថៃឱ្យតែបុរាណ! ចូលចិត្ត។

ក៖ បាទ!

ខ៖ ដូចសព្វថ្ងៃហ្នឹង បើសិនមានទូរទស្សន៍ ខ្សែងស័ង្ករហូត។

ក៖ អូ! ខ្សែងស័ង្គហ្ន៎?

ខ៖ ចាំ! ខ្សែងស័ង្គ។

កៈ បាទ! រឿងនាយងស់អី?

ខៈ ចាំ!

កៈ ងស់?

ខៈ សត្វងស់។

កៈ បាទ! ពេលទំនេរអ៊ុំស្រីចូលចិត្តធ្វើអីដែរ?

ខៈ ខ្ញុំចូលចិត្តដេរខោអាវអោយចៅ។ ដាក់លេវអាវអីអញ្ចឹង! តែមើលអត់ឃើញ។

កៈ បាទ!

ខៈ ទាល់ហៅចៅមកឈុសអីទៅ លេវអាវហែងដាច់អី? ខោអីរហែកថ្មេរមកដេរឱ្យអីចឹង។

កៈ បាទ!

ខៈ តែថ្មេរមួយស្រូវៗ។

កៈ ថ្មេរមួយស្រូវៗ?

ខៈ ចាំ! ដេរឱ្យជិតៗទៅ។

កៈ បានន័យថាថ្មេរធំៗ?

ខៈ ថ្មេរធំៗវែងដែរ។

កៈ បាទ! អញ្ចឹងតាំងពីក្មេងរហូតដល់ឥឡូវនេះលោកយាយ ឬក៏អ៊ុំស្រីចូលចិត្ត។ ចូលចិត្ត ឬក៏ធ្លាប់បានទៅលេងនៅខេត្តណាខ្លះ?

ខៈ ខ្ញុំបានទៅតែសៀមរាបអង្គរ។

កៈ សៀមរាបអង្គរវត្តណាំ?

ខៈ ចាំ!

កៈ ប្រាសាទអី?

ខៈ ប្រសាទអង្គរធំ អង្គរតូច។

កៈ បាទ!

ខៈ ចាំ! ប៉ុណ្ណឹងឯង។

កៈ បានទៅលេងបារាយអត់?

ខៈ អត់! អត់បានទៅផង។

កៈ បានទៅលេងភ្នំគូលែនអត់?

ខៈ អត់ទេ។

កៈ បានទៅលេងភូមិវត្តធម៌អត់?

ខៈ ភូមិវត្តធម៌បាន។

កៈ បានទៅហ្ន៎?

ខៈ ចាំ!

កៈ សប្បាយអត់?

ខៈ សប្បាយតា ឃើញវត្ថុបុរាណៗច្រើន។

កៈ បាទ!

ខៈ ចាំ!

កៈ ឃើញវប្បធម៌ច្រើនហ្ន៎?

ខៈ ប៉ុនគេទៅល្ងាច។គេអត់សម្រាកណា គេទៅល្ងាចណា មកវិញល្ងាចបានសម្រាកមួយភ្លែតៗ។

កៈ អូ! បាទ! អញ្ចឹងធ្លាប់បានទៅលេងកំពង់ធំអត់?

ខៈ អត់ទេ! បើកំពង់សោមបាន។

កៈ អូ! កំពង់សោម ហើយធ្វើមិចបានទៅកំពង់សោម?

ខៈ កូនទៅធ្វើការឯណោះ។

កៈ អ៎!

ខៈ ចា៎!

កៈ ទៅបានប៉ុន្មានថ្ងៃ?

ខៈ ទៅបាន១ខែ។

កៈ អូ! យូរ។

ខៈ ចា៎! កូននៅធ្វើការហ្នឹងទៅលេង តែអត់ហ៊ានងូតទឹកទេ ខ្លាចខ្យល់បោក។

កៈ ទៅបានប៉ុន្មានខែ?

ខៈ ទៅបាន១ខែ។

កៈ អ៎! ចង់និយាយថាទៅបានប៉ុន្មានឆ្នាំហើយ?

ខៈ អ៎! ជិត៣ឆ្នាំហើយ។

កៈ អ៎! ៣ឆ្នាំហើយហ្ន៎?

ខៈ ចា៎!

កៈ ចង់ទៅលេងទៀតនៅ?

ខៈ អេ! ពិបាកជិះឡាន។

កៈ ពិបាកជិះឡានហ្ន៎?

ខ៖ ឈើខ្នង ឈើចង្កេះ។

ក៖ បាទ! នៅក្នុងក្រុមគ្រួសាររបស់អ៊ុំស្រី ឬក៏លោកយាយមានអ្នកចេះលេងតន្ត្រីទេ?

ខ៖ អត់ទេ។

ក៖ អត់ទេហ្ន៎?

ខ៖ ចាំ!

ក៖ ចុះមានអ្នកដែលចូលចិត្តកីឡាប្រដាលអត់?

ខ៖ អត់! អត់មានណាដាលផង។

ក៖ ចូលចិត្តមើលកីឡាប្រដាល់?

ខ៖ អាហ្នឹងចូលចិត្ត។ កូនប្រសារខ្ញុំ។

ក៖ គាត់ចូលចិត្តមើលណ៎?

ខ៖ ចាស់! ខាងព័ត៌មាន ខាងប្រដាលអី។

ក៖ ចុះទាក់ទងនឹងកន្ទ្រឹម សារ៉ាវ៉ាន់ ឡាំលាវ ចូកក្រពឺស អង្គុញ ឈូកអីមានអ្នកចូកចិត្តអត់?

ខ៖ ខ្ញុំ?

ក៖ ខ្ញុំហ្នឹងឯង?

ខ៖ ខ្ញុំហ្នឹងវល់។

ក៖ កាលហ្នឹងលោកយាយអាយុប៉ុន្មានហើយ? រាំលេង?

ខ៖ ខ្ញុំលេង រាំលេងតាំងពីខ្ញុំនៅតូច អូ! តាំងមុនដំបូងជីកដីអញ្ចឹងទៅដាក់ថាសទៅ យកមក ដាក់ប៉ោតអីចឹង ដាក់ចង់បង្គោលមួយដាក់ខ្សែគោមួយដំទៅ។

ក៖ បាទ!

ខ៖ រាំលេងទៅ។ តាៗគាត់ធ្វើអញ្ចឹង ទិញស្គរដើមួយ ហើយទ្រ។

ក៖ បាទ!

ខ៖ គួសទុងៗទុករាំ។

ក៖ បាទ!

ខ៖ អត់ចេះច្រៀង ចង់ច្រៀងចង់រាំរហូតដល់ខ្ញុំបង្កើតបានបាស់។ ចេះចង់រាំចង់ច្រៀងរហូរត ដល់ឥឡូវ។

ក៖ បាទ! អូ! កាលហ្នឹងគេមានស្គរមានអី គួសតាក់ទុងៗ?

ខ៖ ចាំ! អាហ្នឹងស្គរដេញស្នួលឈើ ទ្រមួយទៅ តាៗកូតទៅ យើងរាំវង់រាំអី ផ្កាល្ហុងអី ស្អីហ្នឹង ទៅ។

ក៖ បាទ!

ខ៖ ផ្ការំចេក សត្វសារីកាអីទៅហើយ។

ក៖ ទៅចប់មកដល់ឥឡូវ?

ខ៖ ចប់មកដល់ឥឡូវហ្នឹង។

ក៖ បាទ។

ខ៖ ឥឡូវស្រុកនេះអ្នកណាក៏ល្បី ថាខ្ញុំរាំដែរ។

ក៖ បាទ! រាំហើយចេះច្រៀងទៀតណំា?

ខ៖ ចាំ! ចេះច្រៀងតិចៗ។

ក៖ មិនច្រៀងឱ្យច្រើន។ ចុះផ្ទះរបស់លោកយាយសាងសង់ពីឈើ ឬក៏ពីថ្ម?

ខ៖ ពីឈើ។

ក៖ ផ្ទះពីដើម?

ខ៖ ផ្ទះពីដើមឈើ។

ក៖ បាទ! ហើយសសរធ្វើពីអី?

ខ៖ ឈើទាំងអស់។

ក៖ ចុះដំបូលផ្ទះធ្វើពីអី?

ខ៖ ប្រក់ស្លឹកត្នោត។

ក៖ ស្លឹកត្នោត?

ខ៖ ចាំ!

ក៖ ហើយជញ្ជាំងធ្វើពីអី?

ខ៖ ជញ្ជាំងគាបស្លឹកត្នោត។

ក៖ បាទ! ហើយចុះបង្អួច?

ខ៖ បង្អួចវាយស្លឹកត្នោតដែរ។

ក៖ ស្លឹកត្នោត?

ខ៖ ចាំ!

ក៖ ហើយចុះរបងផ្ទះធ្វើពីអី?

ខ៖ របងផ្ទះស្រះប្រឡា។

ក៖ បាទ! ហើយទំហំដីធំទេពីមុនមក?

ខ៖ ធំតា! ដី១០០ម៉ែត្រជាងដែរដឹង?

ក៖ អូ! នៅខេត្តឯណោះ?

ខ៖ ចាំ! នៅខេត្តស្រុកហ្នឹង ឥឡូវគេយកអស់ហើយ។

កៈ ហើយផ្ទះហ្នឹងជួលជាងសាងសង់ ឬក៏សាងសង់ខ្លួនឯង?

ខៈ ឪខ្ញុំគាត់សាងសង់ខ្លួនឯង។

កៈ បាទ!

ខៈ តែកាលជំនាន់នោះយន្តហោះទម្លាក់ឆេះអស់ហើយ។

កៈ អ៎! ឆេះដោយសារយន្តហោះទៀត?

ខៈ ចា៎! កាល៧០ប៉ុន្មាន? ៧០គត់ ៧១ហ្នឹងឯង។

កៈ ហើយផ្ទះនោះធ្វើប៉ុន្មានថ្ងៃបានហើយ?

ខៈ អត់ដឹងផង កើតមកឃើញតែផ្ទះហ្នឹងប្រដោយ។

កៈ អ៎!

ខៈ ចា៎!

កៈ គាត់ធ្វើអត់ប្រាប់ហ្ន៎?

ខៈ ចា៎! ធ្វើអត់ប្រាប់ខ្ញុំនៅតូច។ គាត់ចេះធ្វើឱ្យកូននៅ។

កៈ ទាក់ទងជំនាញវិញ តើអ៊ុំស្រីធ្លាប់បានរៀន លោកយាយធ្លាប់បានរៀនជំនាញអីខ្លះ? ពីមុនមកទេ?

ខៈ ខ្ញុំកាលលមុនមានរៀនអីធ្វើតែស្រែ ចិញ្ចឹមជ្រូក មើលតែគោហ្នឹងឯង។

កៈ បាទ!

ខៈ មានធ្វើអ្វីផង។

កៈ ធ្វើស្រែ ចិញ្ចឹមជ្រូក មើលគោ។ ដាំដំណាំអត់?

ខៈ ដាំបន្តិចបន្តួចគ្រាន់បានចិញ្ចឹមជីវភាពយើងពីសង្គម។

កៈ ធ្លាប់ដាំដំណាំអ្វីខ្លះ?

ខៈ នៅឯណោះអ្វី?

កៈ បាទ!

ខៈ ដាំអាល្វាង ដាំល្ពៅ ដាំសណ្តែកអីចឹងទៅ។

កៈ បាទ! ចុះធ្លាប់ឡើងត្នោតទេ?

ខៈ ឪខ្ញុំ ហើយនិង បងខ្ញុំអ្នកឡើង។ ខ្ញុំមិនហ៊ានឡើងទេខ្លាច។

កៈ ពួកគាត់ឡើងប៉ុន្មានឆ្នាំហើយ?

ខៈ គាត់ឡើងតាំងពីកម្លោះអីចឹងមក តាំងពីជំទង់អីចឹងមករហូតដល់គាត់មានប្រពន្ធ។

កៈ បាទ!

ខៈ យាយចំតតែពី៧០ គេបែករត់ខ្ចាត់ឆ្ងាយបានគាត់ឈប់ឡើង។

កៈ អ៎! ទឹកត្នោតផ្អែមអត់? ឆ្ងាញ់អត់?

ខៈ ឆ្ងាញ់តើ។

កៈ ទឹកត្នោតគិតថា មានទឹកអីដែលផ្អែមឆ្ងាញ់ដូចទឹកត្នោតអត់?

ខៈ អត់មានទេ មានតែទឹកត្នោត។

កៈ ចុះទឹកអំពៅ ទឹកត្នោតខុសគ្នាមិច?

ខៈ ខុសគ្នា ទឹកត្នោតអត់មានធំក្លិន។

កៈ បាទ!

ខៈ ហ្នឹងហើយ! បើទឹកអំពៅយើងធំខ្លិ សំបកអំពៅ។

កៈ ទៅផ្អូម?

ខ៖ ចាំ! ទឹកត្នោតអត់ធំផ្អម។

ក៖ ទឹកត្នោតទុកយូរកាន់តែឈ្ងុយ?

ខ៖ ចាំ! ហើយកាលមុនធ្វើទឹកត្នោតអីចឹង គេដាក់អំពារ ដល់សម័យបច្ចុប្បន្នក្រោយគេដាក់កំបោរ។

ក៖ អ៎! ដាក់កំបោរ ដាក់អំពារខុសគ្នាមិច?

ខ៖ ចាំ! ដាក់អំពារវាអត់ចេះកាត់ ហើយវាថ្លាល្អ។

ក៖ បាទ!

ខ៖ ហ្នឹងហើយ ដល់ដាក់កំបោរវាធំខ្លិនកំបោរ។

ក៖ អ៎!

ខ៖ អញ្ចឹងបានដើមបំពង់ណាដែលគេហូប គេអត់ដាក់ទេកំបោរ។

ក៖ ធ្លាប់ធ្វើកន្ត្រកលក់អត់ពីមុនមក?

ខ៖ អត់ចេះ! ចេះតែធ្វើចង្អេ។

ក៖ អូ! ចង្អេហ្មំ?

ខ៖ ចាំ! ចង្អេ ធ្វើកញ្ជើ ធ្វើកញ្ជ្រែងអីចឹងឯង ឡើងភ្នំ កាប់ឫស្សី ទូលរែកមក។

ក៖ បាទ! លក់បានច្រើនអត់?

ខ៖ បានមួយៗ មួយ១០រៀល។

ក៖ ១០រៀលខ្មែរហ្មំ?

ខ៖ ១០រៀលខ្មែរពីដើម។

ក៖ បាទ!

ខ៖ យើងចាយលុយអារ្យបខ្យង។

ក៖ បាទ! ធ្លាប់នេសាទត្រីអត់?

ខ៖ ដែលជត់។

ក៖ ជត់?

ខ៖ ជត់ក្នុងទឹកនេះ។

ក៖ បាទ! ចាប់បានអត់?

ខ៖ ចូលគ្នាចាប់ទៅ ចាប់ត្រីតូចៗអីហ្នឹង។

ក៖ បាទ! អញ្ចឹងទាក់ទងនឹងសត្វព្រៃ ធ្លាប់ចិញ្ចឹមសត្វព្រៃអត់?

ខ៖ អត់ទេ។

ក៖ សត្វសារីកា?

ខ៖ អត់!

ក៖ កំប្រុក កាហែង?

ខ៖ អត់ទេ។

ក៖ សត្វដង្កូវនាង?

ខ៖ អត់!

ក៖ ធ្លាប់ចិញ្ចឹមសត្វឃ្មុំអត់?

ខ៖ ខ្ញុំអត់ទេមិនដែលចិញ្ចឹមទេ។

ក៖ បទពិសោធន៍ល្អៗរបស់លោកយាយមានទេ? ពីដើមមក?

ខ៖ មានអីកូន។ មានតែធ្វើស្រែ ធ្វើអីនេះ។

កៈ រាំលេង?

ខៈ រាំលេង។

កៈ សប្បាយតា?

ខៈ ចាស់! ទៅវត្តអីអញ្ចឹងទៅ។ ហើយចូលឆ្នាំឡើងទៅវត្តទៅ ព្រឹកឡើងងូតទឹកទៅវត្តទៀត លេងឈូង លេងអីអញ្ចឹងទៅ។

កៈ អរអំបុក?

ខៈ ចាស់។

កៈ អូ! សប្បាយមួយគំនរ។ ក្តីស្រមៃរបស់លោកយាយ ឬក៏អ៊ំស្រីកាលនៅក្មេង។ ថាធំឡើងចង់ធ្វើអីទេ?

ខៈ កាលខ្ញុំពីក្មេងអរ?

កៈ បាទ។

ខៈ ខ្ញុំនិយាយត្រង់តាំងពី ចង់ច្រៀង។

កៈ បាទ! ធ្វើអ្នកចម្រៀង?

ខៈ តែម៉ែខ្ញុំគាត់អត់អោយទៅ។

កៈ បាទ។

ខៈ អ្នកស្រី សូ សាវឿនហ្នឹងគាត់នៅខាងត្បូងភូមិខ្ញុំ។

កៈ អរ! ជិតហ្នឹងដែរ?

ខៈ ចា៎! ហ្នឹងហើយ។ ហើយគាត់អ្នកលេងល្ខោន ហៅល្ខោនភូមិចាស់។

កៈ បាទ!

ខៈ ឃើញខ្ញុំច្រៀងពិរោះអញ្ចឹងទៅ គាត់ចេះហៅខ្ញុំ សុំខ្ញុំឱ្យទៅ ម៉ែខ្ញុំអត់ឱ្យទៅទេ។

ក៖ បាទ!

ខ៖ ចាំ!

ក៖ កុំអីស្វសារៀនខ្មាស។

ខ៖ ឃើញខ្ញុំឡើងដើមឈើអី ដើមគោអញ្ចឹងខ្ញុំច្រៀង៕